# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាសប្តាហ៍ទី៣នៃរដូវរង់ចាំ នៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០
# ខ្ញុំជាសំឡេង

**អត្ថបទទី១៖ អេសាយ ៦១,១-២ក.១០-១១**

ដីធ្វើឲ្យពន្លក និងគ្រាប់ពូជផ្សេងៗ ដុះឡើងនៅក្នុងសួនច្បារយ៉ាងណា ព្រះជាអម្ចាស់នឹងធ្វើឲ្យសេចក្តីសុចរិត និងការសរសើរតម្កើងផុសចេញពីទឹកដីនេះ នៅចំពោះប្រជាជាតិទាំងប៉ុន្មានយ៉ាងនោះដែរ។ អស ៦១,១១

**អត្ថបទទី២៖ ថេស្សាឡូនិកទី១ ៥,១៦-២៤**

ចូរមានអំណរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ ដ្បិតព្រះអង្គសព្វព្រះហឫទ័យឲ្យបងប្អូន ដែលរួមជាមួយព្រះគ្រីស្តយេស៊ូធ្វើដូច្នេះឯង។ ១ថស ៥,១៦-១៨

**ដំណឹងល្អ៖ យ៉ូហាន ១,៦-៨.១៩-២៨**

ខ្ញុំជាសំឡេងបុរសម្នាក់ដែលស្រែកនៅវាលរហោស្ថានថាៈ ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់” ។ យហ ១,២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាសប្តាហ៍ទី៣នៃរដូវរង់ចាំ ជាពេលវេលាដើម្បីបង្ហាញអំណរសប្បាយ អំណរសប្បាយរួមជាមួយព្រះនាងម៉ារី។ ថ្ងៃនេះយើងបានច្រៀងទំនុកតម្កើងរបស់ព្រះនាងម៉ារី ដើម្បីចូលរួមនៅក្នុងអំណរសប្បាយដ៏ពិសេស ដែលព្រះនាងម៉ារីបានទទួលនៅពេលព្រះនាងដឹងថាខ្លួនទៅជាមាតារបស់ព្រះជាម្ចាស់។ ព្រះនាងម៉ារី បានទៅចែកអំណរសប្បាយនេះទៅយាយអេលីសាបិែត។ ថ្ងៃនេះ ជាពេលវេលាសម្រាប់យើងដែរ **តើយើងធ្វើដូចម្តេចដើម្បីចែករំលែកអំណរសប្បាយនៅក្នុងស្ថានភាពនៃពិភពលោករបស់យើងសព្វថ្ងៃ ជាពិសេសនៅក្នុងសង្គមខ្មែរយើង?**

យើងបានស្តាប់នៅក្នុងគម្ពីរដំណឹងល្អ អំពីតួនាទី អំពីបេសកកម្មរបស់លោកយ៉ូហាន គាត់មានប្រសាសន៍ថា “**ខ្ញុំជាសម្លេងបុរសម្នាក់ ដែលស្រែកនៅក្នុងវាលរហោឋានថា ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់**”។ យើងជាព្រះសហគមន៍កាតូលិក យើងជាគ្រីស្តបរិស័ទនៅលើទឹកដីប្រទេសកម្ពុជា ជាពិសេសនៅក្នុងភូមិភាគភ្នំពេញ **តើយើងធ្វើដូចម្តេចដើម្បីទៅជាសំឡេងរបស់ព្រះជាម្ចាស់នៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ?** សព្វថ្ងៃយើងជួបជុំគ្នាច្រើនមិនបាន យើងបានកាត់បន្ថយសកម្មភាពរបស់យើងយ៉ាងច្រើន ដូចជាសកម្មភាពសាសនា សកម្មភាពសិក្សា កន្លែងដែលមានការជួបជុំគ្នាច្រើន...។ នៅជាយក្រុងភ្នំពេញសព្វថ្ងៃ វាលស្រែចាប់ផ្តើមអស់បន្តិចម្តងៗ គេសាង

សង់ផ្ទះ សាងសង់បុរី គេបានសាងសង់សាលារៀន វត្តអារាម ដោយសារមានមនុស្សរស់នៅច្រើន។ នៅជាយក្រុងភ្នំពេញ ខ្ញុំបានឃើញគេមានជីវិតធម្មតាដោយមិនមានការភ័យខ្លាចជំងឺកូវីដ១៩ ដូចនៅភ្នំពេញ។ ពេលនោះ ខ្ញុំបានសួរខ្លួនឯងថា "**តើខ្ញុំធ្វើដូចម្ដេចដើម្បីថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់? តើខ្ញុំធ្វើដូចម្ដេចដើម្បីផ្ដល់សក្ខីភាពអំពីព្រះយេស៊ូដែលកំពុងយាងមកនៅក្នុងបរិយាកាសថ្មីនៃទីក្រុងភ្នំពេញ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល?**"។

ពេលបានស្ដាប់បេសកកម្មរបស់លោកយ៉ូហាន "**ខ្ញុំជាសំឡេងរបស់បុរសម្នាក់ដែលស្រែកនៅវាលរហោឋាន**"។ វាលរហោឋាន ជាកន្លែងមួយដែលគ្មានអ្វីទាំងអស់ មានតែដីខ្សាច់ សត្វមួយចំនួន នេះដូចជាលោកយ៉ូហានបានទៅប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅកន្លែងមួយដែលគ្មានមនុស្សសោះ។ សព្វថ្ងៃ នៅក្នុងសង្គមរបស់យើងមានមនុស្សច្រើនណាស់ ប៉ុន្តែសំឡេងរបស់យើងមិនមែនទៅជាសំឡេងដូចពីសម័យដើម ទោះបីមានមនុស្សច្រើនក៏ដោយ យើងធ្វើដូចម្ដេចដើម្បីឲ្យគេស្ដាប់បានដែរ។ ពេលខ្ញុំបានលឺអ្នកលក់ដូរស្រែកពពាយនាយតាមឧគ្ឃោសនាសព្ទ(មេក្រូ) ប្រសិនបើខ្ញុំស្រែកថា "**បងប្អូនអើយៗ ព្រះយេស៊ូកំពុងយាងមក តើអ្នកស្ដាប់លឺ? តើយើងធ្វើដូចម្ដេចដើម្បីផ្ដល់សក្ខីភាព?**"។ នេះជាសំណួរដែលខ្ញុំទុក សម្រាប់ព្រះសហគមន៍នីមួយៗនៅក្នុងភូមិភាគភ្នំពេញ **តើកន្លែងដែលយើងនៅ (នៅទីក្រុងក្ដី នៅទីក្រុងថ្មីក្ដី នៅក្នុងភូមិក្ដី) យើងធ្វើដូចម្ដេចដើម្បីទៅជាសំឡេងមួយឲ្យគេលឺបាន ពិតមែនព្រះជាម្ចាស់កំពុងយាងមក?** ជាពិសេសនៅក្នុងបរិយាកាសនៃកូវីដ១៩ ដែលបានណែនាំឲ្យយើងកាត់បន្ថយគ្រប់សកម្មភាពដែលយើងត្រូវតែមាន នៅក្នុងពេលវេលាអំណរសប្បាយនៃរដូវរង់ចាំ ដោយត្រៀមខ្លួនប្រារព្ធបុណ្យព្រះយេស៊ូប្រសូត។

ខ្ញុំដឹងថា បងប្អូនគ្រីស្តបរិស័ទ លោកបូជាចារ្យ បងប្រុសបងស្រី កំពុងព្រួយបារម្ភ **តើយើងធ្វើអ្វីសម្រាប់បុណ្យព្រះយេស៊ូប្រសូត?** គឺយើងត្រូវធ្វើតាមកាលៈទេសៈ។ ប្រហែលយើងបានទទួលចម្លើយនៅក្នុងអត្ថបទទីពីរ "**ចូរមានអំណរសប្បាយជានិច្ច ចូរអធិដ្ឋានឥតឈប់ឈរ ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់**"។ ខ្ញុំជឿថា ទោះបីយើងឥតមានសិទ្ធិជួបជុំគ្នាលើសពី២០នាក់ ទោះបីយើងគ្មានសិទ្ធិធ្វើពិធីបុណ្យព្រះយេស៊ូប្រសូតយ៉ាងធំក៏ដោយ យើងត្រូវតែទុកដួងចិត្តរបស់យើង វិញ្ញាណរបស់យើងនៅក្នុងគោលដៅអំណរសប្បាយជានិច្ច អធិដ្ឋានឥតឈប់ឈរ អរព្រះគុណព្រះជាម្ចាស់នៅក្នុងគ្រប់កាលៈទេសៈ។ នេះជាអត្តសញ្ញាណរបស់យើងជាគ្រីស្តបរិស័ទ ទោះបីមានបញ្ហា ទោះបីយើងជួបជុំគ្នាមិនបានដូចរាល់ឆ្នាំ តែយើងជាប្រជារាស្ត្រនៃសេចក្ដីសង្ឃឹម សេចក្ដីសង្ឃឹមនេះយើងត្រូវតែការពារថែរក្សា។ ដោយដឹងថានៅក្នុងពិភពលោក

មានកន្លែងជាច្រើនដែលមានបញ្ហាខ្លាំងជាងយើងឆ្ងាយណាស់ យើងមានអ្នកជំងឺកូវីដមួយៗ ប៉ុន្តែមានប៉ុន្មានប្រទេសដែលមានអ្នកជំងឺកូវីដរាប់ពាន់នាក់រាល់ថ្ងៃ មានអ្នកស្លាប់យ៉ាងច្រើនរាល់ថ្ងៃ។

ដូច្នេះ យើងត្រូវតែត្រៀមខ្លួនដើម្បីរៀបចំផ្លូវថ្វាយព្រះជាម្ចាស់ ដោយទទួលអ្វីដែលលោកប៉ូលបាននិយាយថ្ងៃនេះ "**កុំរារាំងសកម្មភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធឡើយ**"។ មនុស្សយើងមានច្បាប់ មនុស្សយើងមានគំនិត មនុស្សយើងមានព្រំដែន ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធគ្មានព្រំដែនទេ។ ដូច្នេះ យើងត្រូវការទុកឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងចូលនៅក្នុងសកម្មភាពនីមួយៗនៃព្រះសហគមន៍របស់យើង នៅក្នុងរដូវរង់ចាំនេះ នៅក្នុងបុណ្យព្រះយេស៊ូប្រសូតខាងមុខនេះ។ ដើម្បីឲ្យអំណរសប្បាយដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់ វត្តមានរបស់ព្រះអង្គដែលយាងមកក្នុងពិភពលោកនេះ ទៅជាអំណរសប្បាយដែលយើងមានសមត្ថភាពក្នុងការចែករំលែកជាមួយបងប្អូនឯទៀតៗ។ ខ្ញុំឥតមានចម្លើយមួយសម្រាប់ភូមិភាគភ្នំពេញយើងទាំងមូល ប៉ុន្តែខ្ញុំសង្ឃឹមលើលោកបូជាចារ្យនិងបងប្រុសបងស្រីម្នាក់ៗ ខ្ញុំសង្ឃឹមលើគណៈកម្មការនីមួយៗតាមព្រះសហគមន៍ **តើយើងធ្វើដូចម្តេចកុំឲ្យយើងរារាំងសកម្មភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ? តើយើងត្រូវធ្វើដូចម្តេច ដើម្បីបង្ហាញថាអំណរសប្បាយរបស់យើង ការអធិដ្ឋានរបស់យើង អរព្រះគុណព្រះជាម្ចាស់របស់យើងមាននៅគ្រប់កាលៈទេសៈ ជាពិសេសកាលៈទេសៈបច្ចុប្បន្ននេះ?** ខ្ញុំទុកឲ្យយើងមានគំនិតផ្ទាល់ខ្លួន ឲ្យយើងមានកម្លាំងផ្ទាល់ខ្លួន ដោយដឹងថាពិតមែនយើងត្រូវតែរៀបចំដូចរាល់ឆ្នាំ តុបតែងរោងព្រះយេស៊ូប្រសូត តុបតែងកន្លែងនីមួយៗ ទោះបីគ្មានមនុស្សយ៉ាងច្រើនដូចរាល់ឆ្នាំដែលមកមើល ប៉ុន្តែយើងរៀបចំ។

តាមប្រពៃណីពីដើម យើងមិនទុករោងព្រះយេស៊ូប្រសូតត្រឹមថ្ងៃព្រះអម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សលោកឃើញ ឬថ្ងៃដែលហោរាចារ្យមកថ្វាយបង្គំដល់ព្រះកុមារយេស៊ូទេ។ ប៉ុន្តែ យើងទុកដល់ថ្ងៃទី០២ ខែកុម្ភៈ ជាថ្ងៃដែលព្រះយេស៊ូថ្វាយខ្លួនទៅព្រះវិហារយេរូសាឡឹម ជាថ្ងៃដែលគេថាព្រះយេស៊ូជាព្រះពន្លឺ។ ដូច្នេះ ឆ្នាំនេះខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗក្នុងភូមិភាគភ្នំពេញទុករោងព្រះយេស៊ូប្រសូតរហូតដល់ថ្ងៃទី០២ ខែកុម្ភៈ ដើម្បីឲ្យគ្រីស្តបរិស័ទមានឱកាសច្រើនថ្វាយបង្គំដល់ព្រះកុមារយេស៊ូ។ តុបតែងរោងព្រះយេស៊ូប្រសូត តុបតែងព្រះវិហារ តុបតែងព្រះសហគមន៍នីមួយៗយ៉ាងល្អ ប៉ុន្តែសំខាន់បំផុតឲ្យយើងតុបតែងដួងចិត្តរបស់យើង ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូយ៉ាងកក់ក្តៅ។ ដើម្បីឲ្យអំណរសប្បាយរបស់ព្រះនាងម៉ារី "**ខ្ញុំមានចិត្តអំណរសប្បាយពន់ពេកណាស់ ព្រោះខ្ញុំបានដឹងច្បាស់ថាព្រះអម្ចាស់ទ្រង់សង្គ្រោះ**"។ ឲ្យយើងតុបតែងដួងចិត្តរបស់យើង ដោយរៀបចំចិត្តគំនិតរបស់យើងយ៉ាងច្បាស់លាស់។

សម្ដេចប៉ាប បានប្រកាសតាំងពីថ្ងៃទី០៨ ខែធ្នូកន្លងទៅថ្មីៗនេះថា ឲ្យព្រះសហគមន៍យើងប្រារព្ធឆ្នាំសន្ត យ៉ូសែប សម្រាប់ពេញមួយឆ្នាំ។ សន្ត យ៉ូសែប ជាឪពុកម្នាក់ដែលនៅស្ងៀមស្ងាត់ ជាឪពុកដែលសំឡឹងមើលព្រះយេស៊ូដែលបានប្រសូតហើយ។ ដូច្នេះ ឆ្នាំនេះយើងចូលរួមយ៉ាងជិតស្និទ្ធជាមួយសន្ត យ៉ូសែប នៅក្នុងភាពស្ងៀមស្ងាត់ ដោយសំឡឹងមើលព្រះយេស៊ូ ដោយពោរពេញដោយអំណរសប្បាយ ដោយដឹងថាពិតមែនព្រះសង្គ្រោះបានយាងមកហើយ ពិតមែនព្រះសង្គ្រោះកំពុងបំភ្លឺពិភពលោកយើង និងបំភ្លឺជីវិតរបស់យើង។ ដើម្បីឲ្យយើងអនុវត្តអ្វីដែលយើងបានស្ដាប់នៅក្នុងអត្ថបទទីមួយថ្ងៃនេះ លោកអេសាយបាននិយាយថា "**ខ្ញុំបានទទួលប្រេងអភិសេក ឲ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់ ជួយថែទាំអស់អ្នកដែលបាក់ទឹកចិត្ត ប្រកាសប្រាប់ជនជាប់ជាឈ្លើយថាពួកគេនឹងរួចខ្លួន ហើយប្រាប់អ្នកជាប់ឃុំឃាំងថាពួកគេនឹងមានសេរីភាព ព្រមទាំងប្រកាសពីឆ្នាំដែលព្រះអម្ចាស់សម្ដែងព្រះហឫទ័យមេត្តាករុណា**"។ ឆ្នាំនេះ ដែលជាឆ្នាំសន្ត យ៉ូសែប យើងដឹងថាពិតមែននៅក្នុងពិភពលោករបស់យើង ព្រះសហគមន៍មានសមត្ថភាពដើម្បីបង្ហាញធម៌មេត្តាករុណានៅគ្រប់ទីកន្លែង និងជាពិសេសនៅលើទឹកដីប្រទេសកម្ពុជា។

ដូច្នេះ ខ្ញុំសូមអញ្ជើញបងប្អូនយើងទាំងអស់អធិដ្ឋានជានិច្ច ការពារថែរក្សាសេចក្ដីសង្ឃឹមជានិច្ច ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធអាចបំពេញបេសកកម្មដ៏ពេញលក្ខណៈ កុំឲ្យយើងធ្វើជាឧបសគ្គ។ យើងទូលអង្វរព្រះអង្គ ឲ្យព្រះអង្គធ្វើដំណើរជាមួយយើង ពិតមែនយើងជាសំឡេងដែលស្រែកនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះថា "**ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់**"។ អាម៉ែន៕